# ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា

THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC.
A NON-PROFIT RELIGIOUS INCORPORATION
2925 220th Street East, Hampton, MN 55031 Tel: (651) 463-3101 http://www.wattmunisota.org


# បុណ្យខួបវត្តមុនីសុតារាម ឆ្នាំទី២០
# បុណ្យមហាកតញ្ញូ

ក្រុមអភិបាល និងពុទ្ធបរិស័ទនៃពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា មានបីតិសោមនស្សប្រកបដោយសទ្ធាជ្រះថ្លា នឹងប្រារព្ធពិធីបុណ្យខួបវត្តឆ្នាំទី២០ ដើម្បីរំលឹកនូវអនុស្សាវរីយ៍ និងឧបការគុណនៃព្រះសង្ឃ ក្រុម អភិបាល សមាជិក សមាជិកា ពុទ្ធបរិស័ទ ក្នុងរដ្ឋមិនីសូតា និងរដ្ឋនានាដែលបានសាមគ្គីស្ថាបនាឡើងនូវសមិទ្ធិផលនៃសេនាសនៈក្នុងវត្តមុនីសុតារាម សំរាប់ជាទីសក្ការៈបូជានៃមហាជនគ្រប់មជ្ឈដ្ឋាន ។ ក្នុងឱកាសដ៏វិសេសនេះទៀត ក្រុមអភិបាលនៃពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម បានរួបរួមនិងអស់លោកអ្នកជាបុត្រា បុត្រី ចៅប្រុស ចៅស្រី នឹប្រារព្ធពិធីបុណ្យមហាកតញ្ញូ ដើម្បីសំដែងនូវសមានចិត្តគោរពដឹងគុណដ៏ជ្រាលជ្រៅដល់មាតា បិតា ជីតូន ជីតា និងព្រឹទ្ធាចារ្យ ដែលមានព្រហ្មវិហារធម៌ និងសង្គហធម៌ដល់យើងទាំងអស់គ្នា ។

អាស្រ័យហេតុនេះ សូមអញ្ជើញ ជីតូន ជីតា មាតា បិតា លោក លោកស្រី កូនចៅ ចូលរួមបំពេញកុសលដ៏វិសេសនិង អនុមោទនា យកផលានិសង្សនេះឱ្យបានគ្រប់ៗគ្នា ។

## កាលបរិច្ឆេទបុណ្យ

ថ្ងៃសៅរ៍ ១៥កើត ខែស្រាពណ៍ ពស២៥៥២ ត្រូវនិងថ្ងៃទី១៦ សីហា ២០០៨

**វេលាព្រឹកម៉ោង ៩:៣០** ជួបជុំពុទ្ធបរិស័ទ នមស្សការ សមាទានសីល ថ្លែងបុព្វហេតុបុណ្យ រាប់បាត្រ វេរភត្តដល់ព្រះសង្ឃ និងជូនភោជនាហារដល់ មាតា បិតា ជីតូន ជីតានិងព្រឹទ្ធាចារ្យ ។

**រសៀលម៉ោង ១:៣០** រៀបដង្ហែ មាតា បិតា ជីតូន ជីតានិងព្រឹទ្ធាចារ្យប្រទក្សិណព្រះវិហារ ព្រះសង្ឃជយន្តោស្រោចសុគន្ធវារី បន្ទាប់មកជួបជុំពុទ្ធបរិស័ទក្នុងព្រះវិហារ នមស្សការ ថ្លែងគុណកថា សូត្រមន្តចំរើនព្រះជន្ម ព្រះសង្ឃឆាក សំពត់ស និងធម្មវិសេសទេសនា ។

**វេលារសៀលម៉ោង ៥:០០ - ១១:០០** សំដែងរបាំបុរាណ និងសិល្បៈ តូរ្យតន្ត្រី

ថ្ងៃអាទិត្យ ១រោច ខែស្រាពណ៍ ពស ២៥៥២ ត្រូវនិងថ្ងៃទី១៧ សីហា ២០០៨

**វេលាព្រឹកម៉ោង ៩:៣០** ជួបជុំពុទ្ធបរិស័ទ នមស្សការ សមាទានសីល ថ្លែងធម្មកថា រាប់បាត្រ វេរភត្ត ដល់ព្រះសង្ឃ និងជូនភោជនាហារដល់មាតា បិតា និងព្រឹទ្ធាចារ្យ ។

**រសៀលម៉ោង ១:០០** ពិធីចែកសិក្ខូបករណ៍ដល់សិស្សានុសិស្ស ។

សេចក្តីបញ្ជាក់ : មាតា បិតា ជីតូន ជីតា និងព្រឹទ្ធាចារ្យ សូមត្រៀមសំលៀកបំពាក់១កំប្លេ សំរាប់ស្រោចទឹក និង១កំប្លេ សំរាប់ស្លៀកពាក់ចូលរួមពិធីសូត្រមន្ត ជាពិសេស សូមពាក់អាវពណ៌សឱ្យបានគ្រប់ៗគ្នា ។